# តើអនុសញ្ញា ស៊ី-ដ គឺជាអ្វី?

• អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (ស៊ី-ដ) គឺជាអនុសញ្ញាអន្តរជាតិស្ដីពី សិទ្ធិមនុស្សដ៏ពិស្ដាជាងគេដែលផ្ដោតសំខាន់ទៅលើបញ្ហាស្ត្រី ហើយអនុសញ្ញានេះតែងត្រូវបានគេពិពណ៌នាថាជាច្បាប់អន្តរជាតិសម្រាប់សិទ្ធិស្ត្រី។ អនុសញ្ញានេះត្រូវបានអនុម័តនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩ ក្នុងអំឡុងពេលសម័យប្រជុំលើកទី៣៤ របស់មហាសន្និបាតអង្គការសហប្រជាជាតិ។

• ពិធីសារបន្ថែមលើអនុសញ្ញា ស៊ី-ដ ត្រូវបានអនុម័តនៅឆ្នាំ១៩៩៩។ ពិធីសារបន្ថែមនេះបង្កើតឡើងដើម្បីឱ្យមាននិតីវិធីបណ្ដឹងបុគ្គល ដែលអនុញ្ញាតឱ្យរូបវន្តបុគ្គលមកពីរដ្ឋភាគីចូលរួមជាមួយ ស៊ី-ដ ក្នុងការដាក់ពាក្យបណ្ដឹងដោយផ្ទាល់ទៅកាន់គណៈកម្មាធិការស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ("គណៈកម្មាធិការ ស៊ី-ដ")។ គណៈកម្មាធិការនឹងវិភាគទៅលើពាក្យបណ្ដឹងទាំងអស់និងភស្ដុតាងពីបុគ្គល និងរដ្ឋដើម្បីសម្រេចចិត្តថាតើមានការរំលោភបំពានដោយផ្អែកលើ ស៊ី-ដ ដែរឬទេ។

• រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់សច្ចាប័នលើអនុសញ្ញា ស៊ី-ដ នៅឆ្នាំ១៩៩២ និងផ្ដល់សច្ចាប័នលើពិធីសារបន្ថែមលើអនុសញ្ញា ស៊ី-ដ នៅឆ្នាំ២០១០។

អនុញ្ញា ស៊ី-ដ ឱ្យនិយមន័យនៃពាក្យ "ការរើសអើងប្រឆាំងនឹងនារីភេទ" គឺសំដៅដល់ការប្រកាន់បែងចែក ការផាត់ចេញ ការរឹតត្បិតដោយផ្អែកលើភេទដែលមានអានុភាព ឬមានបំណងធ្វើឲ្យខូចខាត ឬធ្វើឲ្យមោឃៈនូវការទទួលស្គាល់ ការអាស្រ័យផល ឬការប្រើប្រាស់ដោយស្ត្រី ដោយឥតគិតដល់ស្ថានភាពអាពាហ៍ពិពាហ៍របស់ស្ត្រី ដោយផ្អែកលើសមភាពរវាងបុរស និងស្ត្រី នូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានក្នុងការចូលរួមនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ ស៊ីវិល ឬក្នុងវិស័យដទៃផ្សេងៗទៀត។"

## អនុសញ្ញា ស៊ី-ដ តម្រូវឱ្យរដ្ឋភាគីទាំងអស់ត្រូវ៖

• អនុម័តច្បាប់ដែលសមស្រប និងហាមឃាត់រាល់ទម្រង់នៃការរើសអើងដែលប្រឆាំងនឹងនារីភេទ

• ធានានូវការការពារដែលមានប្រសិទ្ធិភាពដល់ស្ត្រីដើម្បីប្រឆាំងគ្រប់ទម្រង់នៃការរើសអើង

• ទប់ស្កាត់រាល់គ្រប់សកម្មភាព ឬការប្រព្រឹត្តនៃការរើសអើងដែលប្រឆាំងនឹងនារីភេទ

• អនុវត្តរាល់គ្រប់វិធានការសមស្រប រួមមានទាំងវិធានការបណ្ដោះអាសន្នដើម្បីពន្លឿនឱ្យមានសមភាពរវាងបុរស និងស្ត្រី និងដើម្បីលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទពីគ្រប់បុគ្គល ស្ថាប័ន ឬក៏សហគ្រាស

• អនុវត្តរាល់គ្រប់វិធានការសមស្របដើម្បីកែប្រែ ឬលុបចោលច្បាប់ បទប្បញ្ញត្តិ និងទំនៀមដែលមានស្រាប់ ព្រមទាំងការអនុវត្តទាំងឡាយណាដែលធ្វើឱ្យមានការរើសអើងប្រឆាំងនឹងនារីភេទ។

រដ្ឋភាគីទាំងអស់ត្រូវប្រកាន់យកគ្រប់វិធានការសមស្របទាំងអស់ដើម្បីធានាឱ្យស្ត្រីមានភាពស្មើគ្នាជាមួយបុរស និងមិនមានការរើសអើងប្រឆាំងនឹងនារីភេទ នៅក្នុងវិស័យដូចខាងក្រោមនេះ៖

ការបោះឆ្នោត

សិទ្ធិក្នុងការចូលរួមដោយពេញលេញនៅក្នុងវិស័យនយោបាយ និងជីវភាពសាធារណៈដោយរួមបញ្ចូលទាំងសិទ្ធិបោះឆ្នោត សិទ្ធិឈរឈ្មោះបោះឆ្នោតសម្រាប់អង្គការសាធារណៈ និងជាអ្នកតំណាងប្រទេសរបស់ខ្លួននៅថ្នាក់អន្តរជាតិផងដែរ។

សិទ្ធិក្នុងការទទួលបានសេវាថែទាំសុខភាពរួមមានមធ្យោបាយទាក់ទងនឹងផែនការគ្រួសារផងដែរ។

សិទ្ធិរបស់ស្ត្រីនៅតាមជនបទ៖ រដ្ឋភាគីត្រូវតែគិតគូ និងដោះស្រាយបញ្ហាជាក់លាក់ដែលស្ត្រីនៅជនបទប្រឈមមុខ។

សិទ្ធិទទួលបានភាពស្មើគ្នានៅចំពោះមុខច្បាប់ សិទ្ធិកាន់កាប់ និងអនុវត្តច្បាប់ដោយពេញលេញក្នុងរឿងរដ្ឋប្បវេណី។

សិទ្ធិក្នុងការជ្រើសរើសគូស្រករ និងរៀបអាពាហ៍ពិពាហ៍ដោយសេរី តែនៅពេលណាដែលពួកគេព្រមព្រៀងគ្នាដោយសេរី និងដោយពេញលេញប៉ុណ្ណោះ និងសិទ្ធិទទួលទ្រព្យសម្បត្តិក្នុងចំណងអាពាហ៍ពិពាហ៍។

សិទ្ធិក្នុងការទទួលបានការអប់រំ ការណែនាំខាងវិជ្ជាជីវៈ និងឱកាសការងារ។

សិទ្ធិក្នុងការទទួលផ្លាស់ប្តូរ ឬរក្សាទុកសញ្ជាតិរបស់ខ្លួន ជាពិសេសស្ថានភាពអាពាហ៍ពិពាហ៍ នឹងមិនធ្វើឱ្យប៉ះពាល់ដល់សញ្ជាតិរបស់ស្ត្រី។

## ដំណើរការនៃការពិនិត្យឡើងវិញ

រដ្ឋភាគីមានកាតព្វកិច្ចក្នុងការដាក់របាយការណ៍ជាទៀងទាត់ជូនគណៈកម្មាធិការជារៀងរាល់ ៤ ឆ្នាំ ម្តង ។




រដ្ឋភាគីធ្វើសេចក្តីព្រាងរបាយការណ៍ឡើងដើម្បីបង្ហាញដល់គណៈកម្មាធិការអំពីសិទ្ធិណាខ្លះនៅក្នុងអនុសញ្ញា ស៊ី-ដ បានអនុវត្តកន្លងមកតាំងពីការពិនិត្យឡើងវិញនៅវដ្តមុន។

អង្គការមិនមែនរដ្ឋាភិបាលអាចដាក់ជូនរបាយការណ៍ស្រមោលរបស់ប្រទេសទៅគណៈកម្មាធិការនេះ។ របាយការណ៍ទាំងនេះគឺជាព័ត៌មានបន្ថែម និង/ឬ ព័ត៌មានផ្សេងទៀតទៅលើរបាយការណ៍របស់រដ្ឋភាគី។

ក្រុមការងារមុនវគ្គដែលមានសមាសភាពសមាជិកនៃគណៈកម្មាធិការ ចំនួនប្រាំរូប ជាអ្នកចងក្រងបញ្ជីបញ្ហានិងសំណួរដែលបានមកពីរបាយការណ៍របស់រដ្ឋភាគីនិងរបាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលហើយបញ្ជីបញ្ហានេះនឹងដាក់ជូនទៅកាន់រដ្ឋភាគី។

រដ្ឋភាគីឆ្លើយតបទៅនឹងបញ្ជីបញ្ហា និងសំណួរ។ អង្គការមិនមែនរដ្ឋាភិបាលដាក់ជូនបច្ចុប្បន្នភាពនៃរបាយការណ៍ស្រមោល។

គណៈកម្មាធិការចូលរួមក្នុងកិច្ចសន្ទនាជាមួយតំណាងរដ្ឋភាគីដើម្បីពិនិត្យឡើងវិញនូវការអនុវត្តអនុសញ្ញា ស៊ី-ដ ។

គណៈកម្មាធិការអនុម័តយកសេចក្តីសន្និដ្ឋានសម្រេចទៅលើវឌ្ឍនភាព និងផលវិបាកការអនុវត្តអនុសញ្ញា ស៊ី-ដ និងការផ្តល់ជាអនុសាសន៍។

រដ្ឋភាគីត្រូវបានស្នើសុំឱ្យមានការតាមដានជាពិសេសទៅលើការអនុវត្តអនុសាសន៍ដែលគណៈកម្មាធិការបានកំណត់។


ឧបត្ថម្ភដោយ

EUROPEAN UNION

DCA actalliance

ផលិតដោយ

VOICES for GENDER EQUALITY

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

@CCHRCambodia @CCHRCambodia @EU.Cambodia



CC BY NC SA


ខែមិថុនា ឆ្នាំ២០២០